20. បិតាអើយ សូមដឹកនាំអ្នកដែលធ្វើការបកប្រែ
និងផលិតកម្មវិធីថ្មី Precious & Beloved។
តាមរយៈកម្មវិធីនេះសូមអោយស្ត្រីនៅប្រទេសស៊ែប៊ី
និងក្រូអាតបានទទួលដឹងពីសេចក្ដីស្រឡាញ់របស់ទ្រង់
ហើយស្វែងរកសេចក្តីល្អ
និងតម្លៃរបស់ពួកគេនៅក្នុងទ្រង់ផងដែរ។ (១ពេត្រុស៣:៤)

21. ព្រះអង្គអើយ
មពង្រឹងសេចក្ដីជំនឿរបស់ស្ត្រីគ្រីស្ទាននៅប្រទេសរ៉ូម៉ានី
អោយពួកគេធ្វើជាសាក្សីដ៏ស្មោះត្រង់របស់ទ្រង់ក្នុងពេលដែ
លមានទុក្ខលំបាក។ (ម៉ាថាយ៥:១៣-១៦)

22. ព្រះអម្ចាស់អើយ សូមផ្ដល់ព្រះគុណ ប្រទានប្រាជ្ញា
និងការថ្វៃប្រឌិតដល់ក្រុមការងារស្ត្រីក្នុងក្ដីសង្ឃឹមនៅប្រទេ
សPortugalក្នុងការដែលពួកគេបង្កើតអត្ថបទថ្មីសម្រាប់ក
ម្មវិធី និង ព័ន្ធកិច្ចផងដែរ។ (សុភាសិត២:៦)

23. បិតាអើយ
យើងសូមអធិស្ឋានសម្រាប់ការការពារមុខតំណែងនៅក្នុង
សង្គម សុខុមាលភាព
និងសុវត្ថិភាពផ្លូវច្បាប់របស់ស្ត្រីនៅប្រទេសប៉ូឡូញ។
សូមទ្រង់ធ្វើជារបងការពារ និង
ជាប្រភពនៃការផ្គត់ផ្គង់របស់ពួកគេផងដែរ។
(ទំនុកតម្កើង៥:១១)

24. ឱព្រះវរបិតាអើយ
ទូលបង្គំអធិស្ឋានសម្រាប់ប្រាជ្ញាដល់ក្រុមស្ត្រីអ្នកស្ដាប់នៅ
Caucasus
ខាងជើងដែលមានការលំបាកក្នុងចំណងអាពាហ៍ពិពាហ៍រប
ស់ពួកគេ។
សូមឱ្យពួកគេបានរកឃើញក្ដីសង្ឃឹមថ្មីដែលមាននៅក្នុងក្ដី
ស្រលាញ់របស់ទ្រង់។ (យ៉ាកុប១:១២)

25. ព្រះអម្ចាស់
កូនសូមអរព្រះគុណទ្រង់សម្រាប់ជោគជ័យកម្មវិធីស្ត្រីក្នុងក្ដី
សង្ឃឹមនៅប្រទេសអាល្លឺម៉ង់
ទទួលបានពីការជួបជុំរបស់ស្ត្រីដើម្បីអធិស្ឋាននៅក្នុងឆ្នាំ20
22 កន្លងទៅនេះ
ហើយក៏អរព្រះគុណទ្រង់សម្រាប់អ្នកដែលផ្គត់ផ្គង់ផ្នែកហិរញ្ញវ
ត្ថុដល់ព័ន្ធកិច្ច និង ចូលរួមក្នុងការអធិស្ឋានផងដែរ។
(ម៉ាឡាគី៣:១០)

26. បិតាអើយ សូមកំសាន្តចិត្ត
និងបង្ហាញផ្លូវដល់អស់អ្នកដែលមានទុក្ខព្រួយ
និងមានភាពឯការនៅប្រទេសហ្វាំងឡង់
សូមអោយពួកគេបានឃើញពីសេចក្ដីពិតនៅក្នុងទ្រង់
ហើយដឹងថាពួកគេមិននៅតែម្នាក់ឯងនោះទេ។
សូមជួយពួកគេឱ្យមានទំនាក់ទំនងជាមួយនណាម្នាក់ដែល
អាចជួយពួកគេបាន។ (ចោទិយកថា៣១:៨)

27. ព្រះអម្ចាស់អើយ
សូមអោយការងាររបស់គ្រីស្ទាននៅក្នុងចំណោមសិស្សនៅ
Greenlandបានមានការរីកចម្រើន។
សូមអោយយុវជនទាំងនោះមានសហគមន៍គ្រីស្ទបរិស័ទណា
មួយដែលពួកគេអាចចូលរួមអានព្រះគម្ពីរ
និងស្វែងរកការលើកទឹកចិត្តបាន។ (១ថែស្សាឡូនិច៥:១១)

28. ឱ ព្រះអម្ចាស់អើយ សូមទ្រង់ប្រទានពរ និង
លើកទឹកចិត្តដល់ក្រុមការងារតូចរបស់ស្ត្រីក្នុងក្ដីសង្ឃឹមនៅ
ប្រទេសដាណឺម៉ាក
ហើយជួយអោយពួកគេមានគំនិតថ្មីក្នុងការបម្រើព័ន្ធកិច្ចរ
បស់ទ្រង់ផងដែរ។ (ភីលីព៤:១៣)

29. ព្រះវរបិតាអើយ
យើងអធិស្ឋានសម្រាប់អ្នកម្ដាយនៅលីវនៅក្នុងប្រទេសក្រូ
អាស៊ី ដើម្បី អោយពួកគេទទួល
បានការចូលរួមចំណែក ក្នុងការចិញ្ចឹមកូនទៀងទាត់ពី
អតីតស្វាមីរបស់ពួកគេ។ (ម៉ាថាយ៧:៩)

30. ព្រះអម្ចាស់អើយ
សូមពង្រឹងក្ដីជំនឿក្រុមជំនុំនៅអាល់បានី
ឱ្យពួកគេធ្វើជាពន្លឺនៅក្នុង លោកិយ៍ដ៏ងងឹតនេះ។
សូមឱ្យពួកគេដើរជាមួយស្ត្រីនៅទីនោះដើម្បីជួយពួក
គេអោយរស់នៅប្រកបដោយព្រះគុណ
និងដោយកោតខ្លាចទ្រង់ផងដែរ។ (អេភេសូរ៥:៨)


후원안내

국민은행 851-01-0003-724 북방선교방송

최초 입금 후 사무실로 연락 주시기 바랍니다


# Women of Hope

## Prayer Calendar

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង
100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 65,000នាក់



## 2023. 4.
## ការអធិស្ឋានសម្រាប់ស្ត្រីអឺរ៉ុប 2

ស្ត្រីគ្រប់រូបមានសិទ្ធិដឹងថាតើព្រះដែលបង្កើតនាងឱ្យ
តម្លៃនាងខ្លាំងប៉ុណ្ណា នឹងដឹងនូវ
ផែនការដ៏អស្ចារ្យដែលព្រះមានសម្រាប់នាង។
គ្មានអ្វីដែលស្រស់ស្អាត
និងរំភើបជាងការឃើញការផ្លាស់ប្រែរបស់ស្ត្រីបន្ទាប់
ពីពួកគេបានស្គាល់ព្រះយេស៊ូវ
និងទទួលបានសេចក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់នោះ
ទេ។


**TWR Korea 북방선교방송**

서울특별시 관악구 양녕로 15, 월드빌딩 6층

전화 (02)886-5671 / 이메일 phkorea@twrk.or.kr

**អធិស្ឋានសំរាប់...............**

1. ឱ ព្រះអម្ចាស់អើយ
សូមប៉ះពាល់និងបង្ហាញវត្តមានរបស់ទ្រង់ទៅកាន់មនុស្សឯកា
នៅប្រទេសស៊ុយអែតដែលមានអារម្មណ៍ថាជីវិតពួកគេហាក់បី
ដូចជាគ្មានន័យ។
សូមជួយពួកគេឱ្យឆ្លងផុតពីអ្វីដែលជម្រុញអារម្មណ៍នៃភាពឯក
ការនេះផងដែរ។ (ទំនុកតម្កើង៣៦:៩)

2.ចំនួននៃស្ត្រីជនអន្តោប្រវេសន៍នៅក្នុងប្រទេសអេស្ប៉ាញមាន
ការកើនឡើងយ៉ាងខ្លាំងក្នុង
រយៈពេល10ឆ្នាំចុងក្រោយនេះ។ បិតាអើយ
សូមការពារពួកគេពីការជួញដូរផ្លូវភេទ ប្រទានពរនិង
កែលម្អជីវិតពួកគេអោយមានភាពល្អប្រសើរឡើងវិញ។
(ចោទិយកថា១០:១៨-១៩)

3. ព្រះអង្គអើយ
សូមទ្រង់ដកចេញការជះឥទ្ធិពលអវិជ្ជមាននៃប្រព័ន្ធសង្គមដែ
លមានការប៉ះពាល់ទៅលើស្ត្រី យុវជន
និងក្មេងស្រីនៅប្រទេសស៊ែប៊ី។
សូមប្រើប្រាស់កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមរបស់TWR
នៅទីនោះក្នុងការអប់រំយុវជនឱ្យរកឃើញអត្តសញ្ញាណពិតរបស់
ពួកគេនៅក្នុង ទ្រង់។ (អេសេគាល៣៦:២៦-២៧)

4. ព្រះវរបិតាអើយ
យើងអធិស្ឋានសម្រាប់ការបំផុសគំនិតថ្មីៗសម្រាប់ក្រុមការងារ
រ៉ូម៉ានារបស់យើងក្នុងការដែលពួកគេសរសេរកម្មវិធីស្ត្រីក្នុងក្តីស
ង្ឃឹម។ សូមផ្តល់មេរៀនដែលមានអត្ថន័យ
និងវាគ្មិនដែលអាចជួយអ្នកស្តាប់ឱ្យស្គាល់ និង
ទទួលបានក្តីស្រលាញ់របស់ទ្រង់កាន់តែច្រើនផងដែរ។
(ទំនុកតម្កើង៤០:១០)

5. បិតាអើយ
សូមស្តារឡើងវិញនូវស្ថានភាពសេដ្ឋកិច្ចនៅប្រទេសព័រទុយហ្គាល់
ដែលកំពុងមានការធ្លាក់ចុះ
ដើម្បីអោយប្រជាជននៅទីនោះអាចមានលទ្ធភាពទិញនូវអា
ហារក្នុងតម្លៃមួយដែលសមរម្យ។ (ម៉ាថាយ៦:២៥)

6. នៅ Greenland មានកុមារចំនួន ៣៧%
ដែលរស់នៅដោយគ្មានឪពុក។ បិតាអើយ សូមប្រទានកម្លាំង
និងពង្រឹងសមត្ថភាពម្តាយដែលនៅមេម៉ាយក្នុងការមើលថែកូ
ន ការធ្វើការងារ និងការសិក្សារបស់កូនផងដែរ។ សូមផ្តល់អ្នក
ដឹកនាំដែលជាបុរសដែលកោតខ្លាចព្រះជាម្ចាស់ក្នុងការ
លើកទឹកចិត្តកុមារទាំងនោះផងដែរ។ (ទំនុកតម្កើង៦៨:៥)

7. ព្រះអម្ចាស់អើយ
សូមប្រទានប្រាជ្ញាដល់អ្នកដឹកនាំនៅប្រទេសប៉ូឡូញ
ក្នុងការកែលម្អសេវាកម្មសុខភាពសម្រាប់ស្ត្រីនៅទីនោះ
និងការបង្កើនប្រាក់ចំណូលដល់ក្រុមគ្រូពេទ្យនៅទីនោះដើម្បីកុំ
អោយពួកគេបង្ខំចិត្តធ្វើការចំណាកស្រុកទៅស្វែងរកការងារដែ
លមានប្រាក់ខែច្រើននោះឡើយ។ (យ៉ាកុប១:៥)

8. ឱ ព្រះជាម្ចាស់អើយ
យើងអធិស្ឋានសុំទ្រង់ប្រទាននូវសេដ្ឋកិច្ចគ្រប់គ្រាន់ដល់ព័ន្ធកិ
ច្ចស្ត្រីក្នុងក្តីសង្ឃឹមនៅប្រទេសន័រវេស ដើម្បីអោយពួកគេអាច
ចែកចាយដំណឹងល្អជាមួយ
នឹងមនុស្សជាច្រើនទៀតដែលមិនទាន់បានលឺពីដំណឹងល្អនេះ។
(ម៉ាកុស១៦:១៥)

**Phum Roung Chak, Sangkat Kok Kleang,**
**Khan Sen Sok, Phnom Penh**
**ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខរាជធានីភ្នំពេញ )**
**Tel: 092 60 60 51 /086 60 60 56**

9. ព្រះអម្ចាស់អើយ
ស្ត្រីជនជាតិអាល់បានីជាច្រើនកំពុងទទួលរងនូវជំងឺបាក់ទឹកចិ
ត្ត។ សូមនាំមកនូវការព្យាបាលដល់ដួងចិត្ត
និងរូបកាយរបស់ពួកគេ
នៅពេលដែលពួកគេស្រែករកទ្រង់។សូមនាំពួកគេអោយរកឃើ
ញអ្នកណាម្នាក់ដែលអាចជួយពួកគេអោយឆ្លងផុតពីការនេះ
បាន។ (ចោទិយកថា៣១:៨)

10. ព្រះអង្គអើយ
សូមនាំមនុស្សអោយស្គាល់កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមដែលបានចេ
ញផ្សាយជាថ្មីនៅលើវេទិកាផ្សេងគ្នាជាច្រើននៅប្រទេស
Caucasus ខាងជើង ដោយសារតែមានការដាក់ទណ្ឌកម្ម
និងបញ្ឈប់អោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម។
(២កូរិនថូស៤:១៦)

11. ឱ ព្រះវរបិតាដ៏មានមហិទ្ធិឫទ្ធិ
សូមបង្ហាញស្ត្រីដែលធ្វើការជាពេស្យាចារនៅប្រទេសអាឡឺម៉ង់
អោយស្គាល់កម្មវិធីកំណប់មរតករបស់ស្ត្រីក្នុងក្តីសង្ឃឹម
ដើម្បីអោយពួកគេអាចរកឃើញសន្តិភាព
និងជីវិតថ្មីដែលមាននៅក្នុងទ្រង់។ (អេសាយ៤៥:៣)

12. បិតាអើយ សូមប្រទានកម្លាំង
និងការលើកទឹកចិត្តដល់ស្ត្រីដែលមានដួងចិត្តសោកសៅ
និងបាក់ទឹកចិត្តនៅប្រទេសហ្វាំងឡង់
ក្នុងការដែលពួកគេបំពេញការងារនិងទទួលខុសត្រូវលើក្រុម
គ្រួសាររបស់ពួកគេ។ (ម៉ាថាយ១១:២៨)

13. ព្រះអម្ចាស់អើយ
សូមបំបែកច្រវ៉ាក់នៃការញៀនគ្រឿងស្រវឹងរបស់ឪពុកម្តាយ
នៅក្នុង ប្រទេស Greenland និងកោះហ្វារ៉ូ។
សូមឱ្យពួកគេមើលថែកូនរបស់ពួកគេតាមរបៀបដែលព្រះជា
ម្ចាស់ចង់អោយពួកគេធ្វើ។ (សុភាសិត២២:៦)

14. ព្រះអង្គអើយ
សូមអោយមានស្ត្រីដែលចូលរួមកម្មវិធីសន្និសិទ្ធរបស់ស្ត្រីក្នុងក្តីស
ង្ឃឹម នៅថ្ងៃទី 14-16 ខែមេសានៅប្រទេសន័រវេស។
សូមលើកទឹកចិត្តពួកគេអោយមានការចូលរួមកាន់តែសកម្ម
ក្នុងកិច្ចការងាររបស់ទ្រង់។ (១ថេស្សាឡូនិច៥:១១)

15. ឱ ព្រះវរបិតាអើយ
សូមឲ្យប្រជាជននៅប្រទេសដាណឺម៉ាកបានដឹងថាជីវិតរបស់ពួ
កគេម្នាក់ៗពិតជាមានតម្លៃខ្លាំងណាស់
ហើយដឹងថាកុមារគឺជាអំណោយដ៏ពិសេសមកពីព្រះជាម្ចាស់។
(ទំនុកតម្កើង១៣៩:១៣-១៦)

16. យើងសូមសរសើរព្រះនាមទ្រង់
ចំពោះការរីកចម្រើននៃអ្នកតាមដាននិងអ្នកចូលរួមបញ្ចេញ
មតិទៅលើទំព័រហ្វេសប៊ុករបស់កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមនៅប្រទេ
សក្រូអាស៊ី។ (ទំនុកតម្កើង ៧១:៨)

17. ព្រះអម្ចាស់អើយ សូមផ្តល់ការងារនិងផ្ទះដល់ស្ត្រីនៅប្រទេស
អាល់បានី ដែលគេចចេញពីជម្រកដែលពេញដោយការ
បំពាននៅក្នុងស្រុករបស់ពួកគេ ប៉ុន្តែបែរជាមកធ្វើស្ត្រី
ពេស្យាដោយព្រោះពួកគេគ្មានលុយគ្រប់គ្រាន់ក្នុងការ
ចិញ្ចឹមកូនរបស់ពួកគេទៅវិញ។ (ម៉ាថាយ៦:១១)

18. បិតាអើយ
សូមជួយអោយឧក្រិដ្ឋជនវ័យក្មេងនៅក្នុងប្រទេសស៊ុយអែតបា
នលឺពីព្រះនាមទ្រង់ហើយទទួលជឿទ្រង់។ សូមឲ្យពួកគេ
បញ្ឈប់រាល់អំពើដែលបំផ្លាញប្រទេសជាតិខ្លួនគេ
និងជីវិតអ្នកដទៃផងដែរ។ (ម៉ាកុស1:17)

19. ឱ ព្រះវរបិតាអើយ
សូមជួយស្ត្រីចាស់ៗដែលជាគ្រីស្ទាននៅប្រទេសអេស្ប៉ាញដែលបា
នក្លាយជាអ្នកមើលថែកុមារ ដោយសារវិបត្តិគ្រួសារ
និងការលែងលះផង។ (ចោទិយកថា៦:៦-៧)